**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ៤៣៧-សជណ.កស

រាជធានី ភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ:** ករណីសំណើសុំលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ១២ ក្រុមហ៊ុន ស្ថិតនៅក្នុងស្រុក ឈូក ខេត្តកំពត ស្រុកកែវសីមា និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ស្រុកអណ្តូងមាស និងស្រុកអូរយ៉ាដាវ ខេត្ត រតនគិរី ស្រុកសន្ទុក ខេត្តកំពង់ធំ និងស្រុកក្រចេះ ស្រុកសំបូរ និងស្រុកស្នួល ខេត្តក្រចេះ ។

**យោង:** -លិខិតលេខ២៩៨៣ កសក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ចំណារសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១១ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា៖ រាជរដ្ឋាភិបាលបានយល់ព្រមតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលុបគោលការណ៍និងកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន ១២ ហើយដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចនេះ ដើម្បីទុកជាសម្បត្តិរដ្ឋវិញ ។ ក្រុមហ៊ុនទាំង ១២ មានដូចខាងក្រោម៖

១-ក្រុមហ៊ុន វើលដ៍ ត្រីស្តារ អ៊ិនធើធេនមេន (ខេមបូឌា) (WORLD TRISTAR ENTERTAINMENT (CAMBODIA) Co.,Ltd) លើផ្ទៃដីចំនួន ៩.៨០០ ហិកតា ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។

២-ក្រុមហ៊ុន ហ្វឺស បាយអូ-ថេក អេគ្រីខលឈើរល (ខេមបូឌា) (FIRST BIO-TECH AGRICULTURAL (CAMBODIA) Co.,Ltd) លើផ្ទៃដីចំនួន ១០.០០០ ហិកតា ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។

៣-ក្រុមហ៊ុន អាគ្រោ្ហ ហ្វរ៉េស្រ្ទី រីស៊ើច (AGRO FORESTRY RESEARCH Co.,Ltd ) លើផ្ទៃដីចំនួន ៧.០០០ ហិកតា ស្ថិតនៅក្នុងឃុំចុងផ្លាស់ ស្រុកកែវសីមា និងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។

៤-ក្រុមហ៊ុន ហេង អភិវឌ្ឍន៍ (HENG DEVELOPMENT Co.,Ltd ) លើផ្ទៃដីចំនួន ៨.៦៥៨ ហិកតា ស្ថិតនៅក្នុង ស្រុកអណ្តូងមាស ខេត្តរតនគិរី។

៥-ក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន (HENG HEAP INVESTMENT Co.,Ltd) លើផ្ទៃដីចំនួន ៧.០០០ ហិកតា ស្ថិតនៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ។

៦-ក្រុមហ៊ុន ហេង មាន អ៊ិនវេសមេន (HENG MEAN INVESTMENT Co.,Ltd) លើផ្ទៃដីចំនួន ៩១៧ ហិកតា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ។

៧-ក្រុមហ៊ុន ក្រចេះ ស៊ីធី ផៅវ័រ អិលធីឌី (KRATIE CITY POWER Ltd) លើផ្ទៃដីចំនួន ៨០០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ ។

៨-ក្រុមហ៊ុន GOLD MENTHOL II Co.,Ltd លើផ្ទៃដីចំនួន ៨២៤ ហិកតា ស្ថិតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ ។

៩-ក្រុមហ៊ុន MEKONG S.C DEVELOPMENT Co.,Ltd លើផ្ទៃដីចំនួន ៨៣៤ ហិកតា ស្ថិតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ ។

១០-ក្រុមហ៊ុន ក៏ អេស វាយ ខូអិលធីឌី លើផ្ទៃដីចំនួន ៩៥០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ ។

១១-ក្រុមហ៊ុន ស៊ីល ឌីវេឡុបមេន (SEAL DEVELOPMENT Co.,Ltd) លើផ្ទៃដីចំនួន ៩៥០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ ។

១២-ក្រុមហ៊ុន TTY Cooperation Co.,Ltd លើផ្ទៃដីចំនួន ៩២៨ ហិកតា ស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

ប៊ុន_រ៉ូយ

ចម្លងជូនៈ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
-រដ្ឋបាលព្រៃឈើ
-សាលាខេត្ត កំពត
-សាលាខេត្ត មណ្ឌលគិរី
-សាលាខេត្ត រតនគិរី
-សាលាខេត្ត កំពង់ធំ
-សាលាខេត្ត ក្រចេះ
-ឯកសារ-កាលប្បវត្តិ